# ក្រមសីលធម៌របស់អ្នកស្ម័គ្រចិត្ត

ដើម្បីអាចស្ម័គ្រចិត្តជួយនៅ ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា គេតម្រូវឲ្យបេក្ខជនផ្តល់ការពិនិត្យមើលប្រវត្តិរូប បញ្ចប់វគ្គនៃការណែនាំសម្រាប់អ្នកស្ម័គ្រចិត្ត និងយល់ព្រមគោរពតាម ក្រមសីលធម៌របស់អ្នកស្ម័គ្រចិត្ត ដូចតទៅនេះ៖

១. ខ្ញុំនឹងទៅចុះហត្ថលេខានៅការិយាល័យសាលា នៅពេលខ្ញុំទៅដល់ភ្លាម។
២. ខ្ញុំនឹងធ្វើតាមការណែនាំរបស់ រដ្ឋបាល គ្រូ និង/ឬ សមាជិកបុគ្គលិកនានា នៅក្នុងអាគារ។
៣. ខ្ញុំយល់ព្រមរៀបចំខ្លួនឲ្យសមតាមមុខនាទី សុភាពរាបសា គ្រប់ពេលវេលា។ ខ្ញុំដឹងថា អ្នកស្ម័គ្រចិត្តគឺជាគំរូរបស់សិស្ស ខ្ញុំនឹងរៀបចំខ្លួនឲ្យសមតាមអ្វីៗទាំងនេះ។
៤. ខ្ញុំដឹងថា ខ្ញុំទទួលខុសត្រូវចំពោះការគោរពតាម ច្បាប់ និង វិធីសាស្រ្ត របស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា។ ខ្ញុំដឹងថា ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា មានការយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើភាពខុសគ្នា និង រួបរួម សិស្សទាំងអស់។ ខ្ញុំនឹងគោរពតាម ច្បាប់ និង តម្លៃ ទាំងនេះ នៅពេលដែលខ្ញុំកំពុងស្ម័គ្រចិត្ត។ ខ្ញុំនឹងមិននិយាយពីទស្សនៈផ្ទាល់ខ្លួន ឬទស្សនៈនយោបាយ របស់ខ្ញុំជាមួយនឹងសិស្ស នៅពេលដែលខ្ញុំកំពុងស្ម័គ្រចិត្ត។ បើខ្ញុំមានសំណួរអ្វីអំពីបញ្ហាទាំងនេះ ខ្ញុំនឹងសួរគ្រូ ឬនាយកសាលា។
៦. ខ្ញុំនឹងប្រើតែបន្ទប់ទឹកសម្រាប់មនុស្សពេញវ័យតែប៉ុណ្ណោះ។
៧. ខ្ញុំនឹងមិនមានគ្រឿងអាវុធ គ្រប់ប្រភេទ នៅពេលខ្ញុំនៅក្នុងបរិវេណសាលា ឬនៅក្នុងកម្មវិធីរបស់សាលា ដែលនៅក្រៅបរិវេណសាលា។
៨. ខ្ញុំនឹងមិនមាន ឬប្រើថ្នាំជក់ ឬផលិតផលដែលមានជាតិ នីកូទីន (nicotine) ហើយមិនមាន ឬស្ថិតនៅក្រោមឥទ្ធិពលនៃជាតិ សុរា កញ្ឆា ឬ គ្រឿងញៀនដែលខុសច្បាប់ នៅក្នុងបរិវេណសាលា ឬនៅក្នុងកម្មវិធីរបស់សាលា ដែលនៅក្រៅបរិវេណសាលា។
៩. ខ្ញុំដឹងថា ក្នុងរយៈពេលស្ម័គ្រចិត្តនេះ ខ្ញុំអាចដឹងពីព័ត៌មាន ផ្ទាល់ខ្លួន ឬ សម្ងាត់ របស់ សិស្ស ក្រុមគ្រួសារ ឬ បុគ្គលិក។ ខ្ញុំយល់ព្រមរក្សាការសម្ងាត់នៅក្រៅសាលា។ ខ្ញុំនឹងមិននិយាយអំពីព័ត៌មានរបស់ សិស្ស ឬ បុគ្គលិក ណាដែលខ្ញុំបានដឹង ជាមួយអ្នកណាម្នាក់ឡើយ លើកលែងតែត្រូវការសម្រាប់ករណីកិច្ចជាអ្នកស្ម័គ្រចិត្ត ដូចបានបញ្ជាក់នៅក្នុងក្រមសិលធម៌នេះ។
១០. ខ្ញុំយល់ព្រមចៀសវាង ការកេងប្រវ័ញ្ចពីសិស្ស ឬការជះឥទ្ធិពលអាក្រក់ទៅលើសិស្ស ឲ្យចូលរួមក្នុងអំពើខុសច្បាប់ ឬខុសសីលធម៌ ឬអាកប្បកិរិយាផ្សេងៗទៀត ដែលនាំឲ្យសិស្សទទួលការដាក់វិន័យចំពោះការប្រព្រឹត្តិមិនត្រឹមត្រូវនេះ ទោះជាសិស្ស បាន ឬ មិនបាន ប្រព្រឹត្តនូវអាកប្បកិរិយានេះក៏ដោយ។
១១. ខ្ញុំយល់ព្រម មិនយាយីផ្លូវភេទរបស់ សិស្ស អ្នកស្ម័គ្រចិត្តដទៃទៀត ឬក៏បុគ្គលិកសាលា។ ខ្ញុំនឹងចៀសវាងការប៉ះពាល់សិស្សដែលមិនសមរម្យ ទោះជានៅក្នុង ឬក្រៅបរិវេណសាលាក៏ដោយ ដែលរួមទាំងការប៉ះពាល់ផ្លូវភេទគ្រប់បែបយ៉ាងទាំងអស់ ទំនាក់ទំនងផ្លូវភេទ ឬទំនាក់ទំនងស្នេហា ការប៉ះពាល់ដែលសិស្សមិនយល់ព្រម ឬ មិនសមរម្យតាម អាយុ ភេទ និង វ័យ របស់សិស្ស។ ខ្ញុំនឹងចៀសវាងការប៉ះពាល់ ឬអោបសិស្ស ទោះជាសិស្សអោបមុនក៏ដោយ។
១២. ខ្ញុំយល់ព្រមផ្តល់ដំណឹងទៅសាលាជាបន្ទាន់ បើសិនជាគេចាប់ខ្ញុំដោយសារការពាក់ព័ន្ធនឹង បទល្មើសមជ្ឈឹម ឬបទឧក្រិដ្ឋ ការរួមភេទ គ្រឿងញៀន ការវាយតប់ ឬ ពាក់ព័ន្ធនឹងគ្រឿងអាវុធ។

**ខ្ញុំយល់ព្រមធ្វើតាមក្រមសីលធម៌របស់អ្នកស្ម័គ្រចិត្តនេះ ស្តង់ដានៃវិជ្ជាជីវៈ និង រក្សាការសម្ងាត់។ ខ្ញុំដឹងថា ការស្ម័គ្រចិត្តគឺជាសិទ្ធិដែលគេផ្តល់អោយ មិនមែនជាសិទ្ធិរបស់ខ្ញុំនោះទេ។ ខ្ញុំដឹងថា ការមិនគោរពតាមក្រមសីលធម៌នេះ អាចបណ្តាលឲ្យគេបញ្ឈប់ខ្ញុំបណ្តោះអាសន្ន ឬ ដកហូតសិទ្ធិស្ម័គ្រចិត្តរបស់ខ្ញុំរហូត ភ្លាមៗ។**

**ឈ្មោះ (សរសេរឲ្យច្បាស់)៖** ______________________________ **ថ្ងៃខែ៖** ______________

**អ៊ីមែល៖** ______________________________ **លេខទូរស័ព្ទ៖** ______________

**ហត្ថលេខា៖** ______________________________

---

***សម្រាប់នាយកសាលា/រដ្ឋបាលសាលា ប្រើ/PRINCIPAL/ADMINISTRATOR USE ONLY***

I certify that the Volunteer Packet of the above listed individual is complete; that I have reviewed the background clearances and determined that there are no offenses or the offenses listed do not prohibit the individual from volunteering; and that this individual may begin volunteering in my school building on the date that I have written below.

**PRINCIPAL/ADMINISTRATOR NAME:** ______________________________

**PRINCIPAL/ADMINISTRATOR SIGNATURE:** ______________________________ **DATE:** ______________